# <u>សារចូលរួមមរណៈទុក្ខ</u>

ក្រុមអង្គការសង្គមស៊ីវិល មានសេចក្តីក្រៀមក្រំ និងសោកស្តាយបំផុតចំពោះព្រឹត្តិការណ៍ដ៏អាក្រក់ ដែលបានកើតឡើងកាលពីរាត្រី ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១០ វេលាម៉ោងប្រហែល ៩:៤៥ នាទី នៅលើស្ពានពេជ្រ ដែលជាស្ពានឆ្លងទៅកាន់មណ្ឌលកំសាន្ត កោះពេជ្រ ដែលបណ្តាលឱ្យជនរួមជាតិស្លាប់បាត់បង់ជីវិត ចំនួនប្រហែល ៣៧៥ នាក់ និងរងរបួសជាច្រើន រយនាក់ ។

ជារៀងរាល់ឆ្នាំនៅក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក បានប្រារព្ធធ្វើឡើងនៅរាជធានីភ្នំពេញ ដែលមានរយៈពេល ៣ ថ្ងៃ ហើយឆ្នាំនេះពិធីបានប្រព្រឹត្តទៅនៅថ្ងៃទី ២០-២២ ខែវិច្ឆិកា ឆ្នាំ២០១០ ដែលមានជនរួមជាតិជាង ៣ លាន នាក់ មកពីគ្រប់ទិសទីក្នុងព្រះរាជាណាចក្រកម្ពុជា បានមកកំសាន្ត។ ជាអកុសលនៅថ្ងៃចុងបញ្ចប់នៃព្រះរាជពិធីបុណ្យនេះមនុស្សកាន់តែមានចំនួនច្រើនឡើងៗ ធ្វើដំណើរបញ្រ្ចៀតគ្នាដើម្បីចូលទៅកំសាន្តនៅកោះពេជ្រ និងដោយសារតែអាចបណ្តាលមកពីមានការបំភ័យផង ទើបធ្វើឱ្យមនុស្សផ្អើលរត់ជាន់គ្នា និងបញ្រ្ចៀតចាក់ស្រេះនៅចំណុចស្ពានពេជ្រ បណ្តាលឱ្យស្លាប់ និងរងរបួសជាច្រើនរយនាក់ ។

ឆ្លៀតក្នុងឱកាសនេះយើងខ្ញុំទាំងអស់គ្នាជាអង្គការសង្គមស៊ីវិល សូមចូលរួមមរណៈទុក្ខយ៉ាងក្រៀមក្រំបំផុត ចំពោះក្រុមគ្រួសារនៃសព និងសូមបួងសួងឱ្យវិញ្ញាណខ័ន្ធ នៃសពទាំងអស់ បានទៅសោយសុខក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ និងសូមឱ្យជនរង គ្រោះទាំងអស់ដែលកំពុងព្យាបាលនៅតាមមន្ទីរពេទ្យនានា ឆាប់ជារួចផុតពីគ្រោះចង្រៃនេះ ។

យើងខ្ញុំទាំងអស់គ្នាជាអង្គការសង្គមស៊ីវិល ក៏សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ឱ្យមានការទប់ស្កាត់នៅពេលខាងមុខកុំឱ្យហេតុការណ៍ បែបនេះកើតមានឡើងទៀតនៅពេលអនាគត ។

ភ្នំពេញ,ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១០

*អង្គការមិនមែនរដ្ឋាភិបាលចូលរួមរំលែកទុក្ខនៅក្នុងព្រឹត្តិការណ៍នេះ រួមមាន:*


-គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ទូរស័ព្ទលេខ: ០១២ ៧១៥ ៨៨៥

-វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) ទូរស័ព្ទលេខ: ០១២ ៩២៨ ៥៨៥

-ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន (HRTF) ទូរស័ព្ទលេខ: ០១២ ៩០៩ ៣៩៧

-គណៈកម្មាធិការខុមហ្វ្រែល (Comfrel) ទូរស័ព្ទលេខ: ០១២ ៩៤២ ០១៧

-គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ（NGOCRC） ទូរស័ព្ទលេខ: ០១២ ៨៨៩ ៤៦៦

-គណៈកម្មាធិការ សហប្រតិបត្តិការ ដើម្បីកម្ពុជា(CCC) ទូរស័ព្ទលេខ: ០១២ ៨០២ ៣៨៤